ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា
និងអធិការកិច្ច
គណៈកម្មាធិការលទ្ធកម្ម

លេខ:០១១/១៩ស.ក.ព.ល.គ.ល

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ ការផ្គត់ផ្គង់ប្រេងឥន្ធនៈ

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបាន ជ្រាបថា៖ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នឹងដាក់ឲ្យដេញថ្លៃ ជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ប្រេងឥន្ធនៈសម្រាប់ឆមាសទី២ ឆ្នាំ២០១៩ ។

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ និងដាក់លក់នៅអង្គភាពលទ្ធកម្ម ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលមានអាស័យដ្ឋានផ្ទះលេខ ១២៦ ផ្លូវលេខ ៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី.០៤...ខែ.សីហា....ឆ្នាំ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទលេខ: ០២៣ ២២១ ៩៦៧) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង០៨:០០នាទីព្រឹក...ថ្ងៃទី.០៣....ខែ.កញ្ញា...... ឆ្នាំ ២០១៩។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តិទៅនៅអង្គភាពលទ្ធកម្ម តាមអាស័យដ្ឋានខាងលើ វេលាម៉ោង០៨:០០នាទី .ថ្ងៃទី....០៣.........ខែ...កញ្ញា..........ឆ្នាំ២០១៩ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញមកទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។/.

ថ្ងៃព្រហស្បតិ៍ ៣ កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ,ថ្ងៃទី......០៤......ខែ..កក្កដា..........ឆ្នាំ២០១៩
ប្រធានគណៈកម្មាធិការលទ្ធកម្ម

បណ្ឌិត. ចាប-សុធារិទ្ធ

ចម្លងជូន

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ